*សង្ខេបគោលនយោបាយ*

# ឆ្ពោះទៅរកការអភិវឌ្ឍប្រកបដោយការទទួលខុសត្រូវ និង បរិយាបន្នបន្ថែមទៀតនៅក្នុងខេត្តព្រះសីហនុ និងខេត្តកោះកុង

***ខ្លឹមសារសំខាន់ៗ***

- *បទប្បញ្ញត្តិ និងមាត្រាស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន (វ.ហ.ប.) មិនទាន់ត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាព ដែលបង្ហាញពីកង្វះខាតជាច្រើននិងសំខាន់ៗនៅក្នុងការអនុវត្តជាក់ស្តែង។*
- *ប្រជាពលរដ្ឋនៅតាមតំបន់ឆ្នេរនៅតែពឹងផ្អែកជាចម្បងទៅលើធនធានផលផលសមុទ្រ បើទោះបីជាមានការអភិវឌ្ឍ និងការវិនិយោគឯកជនជាច្រើនក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។ ការណ៍នេះបង្ហាញពីការពឹងផ្អែកដ៏លើសលប់លើផលផលសមុទ្រសម្រាប់ការចិញ្ចឹមជីវិត និងសកម្មភាពសេដ្ឋកិច្ចក្នុងចំណោមសហគមន៍នៅតាមតំបន់ឆ្នេរ។*
- *ធនធានធម្មជាតិរបស់សហគមន៍កំពុងធ្លាក់ចុះ ដែលនឹងបង្កអស្ថិរភាពសេដ្ឋកិច្ចមូលដ្ឋាននាពេលអនាគតសម្រាប់សហគមន៍ទាំងឡាយ។*
- *អភិបាលកិច្ចដែលគ្មានប្រសិទ្ធភាពរបស់សហគមន៍មូលដ្ឋាន គឺជាកត្តាសំខាន់ដែលបង្កើនល្បឿននៃការថយចុះនៃធនធានធម្មជាតិនៅក្នុងសហគមន៍ជាច្រើនតាមតំបន់ឆ្នេរ។*
- *សម្ពាធពីខាងក្រៅដែលធ្វើឡើងដោយឥស្សរជនជាបុគ្គលដែលមានឥទ្ធិពល និងក្រុមហ៊ុនវិនិយោគឯកជនមកលើតំបន់ឆ្នេរសមុទ្រ និងតំបន់ព្រៃកនានាក្នុងប្រទេសកម្ពុជា គឺជាក្តីកង្វល់ដ៏សំខាន់ និងកំពុងបន្តអស់រយៈពេលជិតមួយទសវត្សរ៍ចុងក្រោយនេះ។*
- *បញ្ហានៃការអនុវត្តច្បាប់ដែលគ្មានប្រសិទ្ធភាពក្នុងការគ្រប់គ្រង និងការពារធនធានធម្មជាតិ ជាពិសេសធនធានសមុទ្រ នៅក្នុងខេត្តជាប់មាត់សមុទ្ររបស់កម្ពុជា ដូចជាខេត្តកោះកុង និងខេត្តព្រះសីហនុ បានលេចចេញជាការព្រួយបារម្ភយ៉ាងខ្លាំង។*
- *បញ្ហានៃព័ត៌មានមានកម្រិតលើផលប័ត្រគម្រោង អ្នកផ្តល់ហិរញ្ញប្បទាន និងគោលនយោបាយទាក់ទងនឹងនិរន្តរភាពនៃគម្រោងវិនិយោគឯកជនតាមតំបន់ឆ្នេរសមុទ្រនៅកម្ពុជា បង្ហាញពីកង្វល់សំខាន់ៗទាក់ទងនឹងតម្លាភាពអាជីវកម្ម សុចរិតភាព និងអភិបាលកិច្ចរួមនៃគម្រោងទាំងនេះ។*

## ១. សេចក្តីផ្តើម

ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន (វ.ហ.ប.) គឺជាកាតព្វកិច្ចចាំបាច់សម្រាប់គម្រោងអភិវឌ្ឍន៍ខ្នាតមធ្យមនិងខ្នាតធំទាំងអស់នៅក្នុងប្រទេសកម្ពុជា រួមទាំងគម្រោងដែលផ្តួចផ្តើមដោយបុគ្គលឯកជន ក្រុមហ៊ុនឯកជន ក្រុមហ៊ុនបណ្តាក់ទុនរួមគ្នា ក្រុមហ៊ុនសាធារណៈ ឬក្រសួង និងទីភ្នាក់ងាររបស់រដ្ឋាភិបាល

។ ក្របខណ្ឌច្បាប់សម្រាប់ការអនុវត្ត វ.ហ.ប. ត្រូវបានបង្កើតឡើងនិងបញ្ចូលទៅក្នុងក្រមបរិស្ថាន និងធនធានធម្មជាតិ ដែលស្របតាមរដ្ឋធម្មនុញ្ញរបស់ប្រទេសកម្ពុជា និងបានសង្កត់ធ្ងន់លើសារៈសំខាន់នៃការការពារបរិស្ថាន និងធនធានធម្មជាតិ។ មានការព្រួយបារម្ភទាក់ទងនឹងហេតុ និងផលប៉ះពាល់នៃគម្រោងវិនិយោគជាច្រើន ជាពិសេសគម្រោងដែលពឹងផ្អែកលើហិរញ្ញប្បទានពីខាងក្រៅប្រទេស។ គម្រោងខ្នាតធំជាច្រើនដែលខ្វះការអនុវត្តដំណើរការ វ.ហ.ប. ឱ្យបានត្រឹមត្រូវ និងមានតម្លាភាព ដែលបានជះឥទ្ធិពលអវិជ្ជមានដល់សិទ្ធិមនុស្ស និងបរិស្ថាន ជាពិសេសតាមរយៈការខូចខាតធនធានក្រោមទឹកនៅតាមតំបន់ឆ្នេរសមុទ្រដែលមានសារៈសំខាន់ចំពោះសហគមន៍នេសាទ។ ក្នុងបរិបទនេះ សម្ព័ន្ធហិរញ្ញវត្ថុយុត្តិធម៌កម្ពុជាបានធ្វើការសិក្សាដើម្បីវាយតម្លៃផលប៉ះពាល់នៃគម្រោងអភិវឌ្ឍន៍លើស្ថានភាពសេដ្ឋកិច្ចសង្គមរបស់សហគមន៍មូលដ្ឋាន និងធនធានជលផលរបស់ពួកគេនៅក្នុងស្រុកព្រៃនប់ ខេត្តព្រះសីហនុ និងស្រុកបទុមសាគរ និងស្រុកស្រែអំបិលក្នុងខេត្តកោះកុង។ ការសិក្សានេះបានពិនិត្យមើលផលប៉ះពាល់អវិជ្ជមាននៃការវិនិយោគ និងគម្រោងអភិវឌ្ឍន៍លើទិដ្ឋភាពបរិស្ថាន និងសកម្មភាពសេដ្ឋកិច្ចរបស់សហគមន៍ដែលរងផលប៉ះពាល់។

ការសិក្សានេះពិនិត្យលើស្ថានភាពសេដ្ឋកិច្ចសង្គម និងធនធានជលផលរបស់សហគមន៍មូលដ្ឋានក្នុងប្រទេសកម្ពុជា ដោយផ្តោតលើផលប៉ះពាល់នៃគម្រោងអភិវឌ្ឍន៍លើសកម្មភាពសេដ្ឋកិច្ច និងទិដ្ឋភាពបរិស្ថានធម្មជាតិ។ ការសិក្សានេះក៏ព្យាយាមកំណត់ស្ថាប័នហិរញ្ញវត្ថុដែលផ្តល់មូលនិធិដល់គម្រោងទាំងនេះ និងវាយតម្លៃការអនុលោមតាមស្តង់ដារសុវត្ថិភាព និងនិរន្តរភាពរបស់ពួកគេផងដែរ។ លទ្ធផលនៃការសិក្សានេះជូនជាធាតុចូល ក៏ដូចជាចំណេះដឹងបន្ថែមដល់ការធ្វើផែនការតស៊ូមតិសម្រាប់សហគមន៍មូលដ្ឋាន និងគាំទ្រដល់ការអនុវត្តក្រមបរិស្ថាន និងធនធានធម្មជាតិឆ្នាំ២០២៣ ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងការគិតគូអំពីស្តង់ដារបរិស្ថាន សង្គម អភិបាលកិច្ច (អ៊ី អេស ជី)[1]។

## ២. វិធីសាស្ត្រនៃសិក្សា

ការសិក្សានេះប្រើវិធីសាស្ត្រទាំងបរិមាណ និងគុណភាព ដើម្បីប្រមូលទិន្នន័យ រួមទាំងការស្ទង់មតិគ្រួសារ និងការសម្ភាសន៍ជាមួយអ្នកផ្តល់ព័ត៌មានសំខាន់ៗ។ ការស្ទង់មតិនេះរួមបញ្ចូលការឆ្លើយតបពី ២៥៤ គ្រួសារនៅតំបន់ដែលមានសក្តានុពលរងផលប៉ះពាល់ពីគម្រោងអភិវឌ្ឍន៍ នៅក្នុងស្រុកព្រៃនប់ ស្រែអំបិល និងស្រុកបុទុមសាគរ។

## ៣. លទ្ធផលនៃការសិក្សា

ការស្ទង់មតិតាមគ្រួសារបានគូសបញ្ជាក់ពីការពឹងផ្អែកជាចម្បងលើជលផលសមុទ្រ ដែលក្នុងនោះមាន ៥៥%, លើធនធានព្រៃកោងកាងមាន ១២%, និងការធ្វើស្រែក្នុងតំបន់ឆ្នេរមាន ១៥%។ ត្រីមានសារសំខាន់ជាងគេ ដែលស្មើនឹង ៤៨% នៃការចាប់ត្រីសរុប (ដ្យាក្រាមទី១)។ ប្រភេទត្រីទាំងនេះក៏រួមបញ្ចូលប្រភេទត្រីដែលមានតម្លៃពាណិជ្ជកម្មខ្ពស់ផងដែរ។ អត្រាភាគរយខ្ពស់នៃធនធានត្រីនៅក្នុងផលចាប់សរុបបានបង្ហាញពីតួនាទីសំខាន់របស់ត្រីជាប្រភពអាហារ ទាំងអាហាររូបត្ថម្ភជាមូលដ្ឋាន និងការទទួលបាន

---

[1] អ៊ី = បរិស្ថាន (E) = Environment, អេស = សង្គម (S) = Social, ជី = អភិបាលកិច្ច (G) = Governance។

ហិរញ្ញវត្ថុសម្រាប់សហគមន៍នៅតាមតំបន់ឆ្នេរផងដែរ។ គ្រួសារភាគច្រើនបានរាយការណ៍ពីប្រាក់ចំណូលរបស់ពួកគេមានចន្លោះពី ២០ ទៅ ២៥០ដុល្លារអាមេរិកក្នុងមួយខែ ជាមួយនឹងជីវភាពរស់នៅផ្តោតលើការនេសាទ ការអាជីវកម្មខ្នាតតូច និងការលក់កម្លាំងពលកម្មប្រចាំថ្ងៃ។ ការសិក្សាបានរកឃើញថា ៦៨% នៃអ្នកឆ្លើយសំណួរជឿថាការប្រមូលធនធានសមុទ្រប្រចាំថ្ងៃមានសារៈសំខាន់ណាស់សម្រាប់ការទប់ទល់នឹងបញ្ហាប្រឈមធម្មជាតិ និងសេដ្ឋកិច្ចសង្គមនានា។ ទោះជាយ៉ាងណាក៏ដោយ ៣១% បានសម្តែងការព្រួយបារម្ភអំពីការថយចុះធនធាន និងសុវត្ថិភាពជីវភាពរស់នៅរបស់ពួកគេ។ ៤០% ជឿថាធនធានបានធ្លាក់ចុះយ៉ាងខ្លាំង ខណៈដែលមានតែ ២៣% ដែលវាយតម្លៃធនធានទាំងនោះបាត់បង់តិចតួច (ដ្យាក្រាមទី២)។




ដ្យាក្រាមទី១៖ ប្រភេទធនធានជលផលសមុទ្រដែលសហគមន៍នេសាទ




ដ្យាក្រាមទី២៖ ការយល់ឃើញរបស់សហគមន៍អំពីកម្រិតនៃការបំផ្លិចបំផ្លាញធនធានសមុទ្រ

ការសិក្សាបានរកឃើញថា ៧២% នៃអ្នកឆ្លើយតបមិនបានដឹងពីគម្រោងវិនិយោគនៅក្នុងតំបន់មូលដ្ឋានរបស់ពួកគេ ខណៈដែល ២៨% មានចំណេះដឹងមានកម្រិតអំពីគម្រោងទាំងនោះ។ ៦៤% បានរាយការណ៍ថាមិនដែលទទួលបានអត្ថប្រយោជន៍ពីគម្រោងទាំងនោះទេ ខណៈពេលដែល ២១% បង្ហាញអារម្មណ៍ថាពួកគេទទួលបានតិចតួចណាស់។ មានតែ ១៥% ប៉ុណ្ណោះដែលបានរាយការណ៍ពីអត្ថប្រយោជន៍ពីមធ្យមទៅច្រើនអំពីគម្រោងទាំងនោះ។ លើសពីនេះ ការស្ទង់មតិបានបង្ហាញថា ប្រជាពលរដ្ឋ ៦៨% មិនបានដឹងពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន (វ.ហ.ប.) ហើយ ៥០,៤% បានរាយការណ៍ថាបានជួបប្រទះផលប៉ះពាល់អវិជ្ជមានពីមធ្យមទៅខ្លាំងពីគម្រោងអភិវឌ្ឍន៍ទាំងនោះ។ ក្ដីកង្វល់របស់ប្រជាពលរដ្ឋក្នុងតំបន់សិក្សាភាគច្រើនផ្តោតទៅលើការត្រួតស៊ីគ្នាលើតំបន់នេសាទ និងរំខានដល់សកម្មភាពនេសាទ និងការធ្វេសប្រហែសនិងមិនយកចិត្តទុកដាក់លើគុណភាពបរិស្ថានពីគម្រោងអភិវឌ្ឍន៍ដែលមាននៅក្នុង ឬនៅក្បែរតំបន់សហគមន៍របស់ពួកគេ។

ភាពជាក់លាក់នៃព័ត៌មានអំពីគម្រោងវិនិយោគ រួមទាំងអត្តសញ្ញាណរបស់អ្នកផ្តល់ហិរញ្ញប្បទានរបស់ពួកគេ នៅតែមិនស្គាល់និងបង្ហាញជាសាធារណៈ។ បញ្ហានេះត្រូវបានគេប៉ាន់ស្មានថាអ្នកផ្តល់ហិរញ្ញវត្ថុទាំងនេះអាចរាប់បញ្ចូលទាំងឧកញ៉ាក្នុងស្រុក ឬអ្នកវិនិយោគឯកជនដែលមានភាគហ៊ុននៅក្នុងគម្រោងទាំងនោះ។ ការបង្ហាញព័ត៌មានមានកម្រិតបង្ហាញពីបញ្ហាប្រឈមជាច្រើន ដែលរារាំងដល់ការយល់ដឹងរបស់អ្នកពាក់ព័ន្ធដែលចូលរួមនៅក្នុងគម្រោងទាំងនោះ ព្រមទាំងសហគមន៍មូលដ្ឋានផងដែរ។ កង្វះតម្លាភាពនេះធ្វើឱ្យប៉ះពាល់ដល់ការយល់ដឹងអំពីតួអង្គដែលបង្កឱ្យមានផលប៉ះពាល់ដល់សហគមន៍មូលដ្ឋាន និងធនធានសមុទ្រនៅក្នុងតំបន់សិក្សា។ អាស្រ័យហេតុនេះ កង្វះខាតដូចដែលបានរៀបរាប់បង្កើននូវការព្រួយបារម្ភអំពីគណនេយ្យភាព និងសមត្ថភាពរបស់សមាជិកសហគមន៍ក្នុងការចូលរួមពិភាក្សាប្រកបដោយអត្ថន័យ ទាក់ទងនឹងផលប៉ះពាល់បរិស្ថាន និងសង្គមនៃការវិនិយោគទាំងនោះ។ ជាងនេះទៅទៀត អវត្តមាននៃក្របខណ្ឌច្បាប់ និងយន្តការអនុវត្តប្រកបដោយប្រសិទ្ធភាពអាចបង្អាក់អ្នកវិនិយោគល្អៗដែលមានសក្តានុពល។ បទប្បញ្ញត្តិមិនគ្រប់គ្រាន់បង្កបញ្ហាប្រឈមសម្រាប់អ្នកវិនិយោគដែលផ្តោតលើអនុលោមភាពដែលទីបំផុតទៅនឹងកំណត់សមត្ថភាពរបស់ប្រទេសកម្ពុជាក្នុងការទាក់ទាញវិនិយោគិនចម្រុះដែលមានការទទួលខុសត្រូវខ្ពស់។

បញ្ហាប្រឈមសំខាន់ៗដែលបានរកឃើញពីការសម្ភាសន៍ និងការពិភាក្សាជាក្រុមរួមមានការអនុវត្តច្បាប់នៅមានកម្រិត, ការត្រួតពិនិត្យមិនទាន់គ្រប់គ្រាន់ទៅលើការការពារតំបន់ការពារធម្មជាតិ, ការកេងប្រវ័ញ្ចធនធានដោយតែភាពក្រីក្ររបស់ប្រជាជននៅតាមមូលដ្ឋាន, ការខ្វះចន្លោះនៃកិច្ចសហការពីភាគីពាក់ព័ន្ធក្នុងការអភិរក្សធនធាន, និង ដំណើរការអនុម័ត និងអនុវត្តការវិនិយោគឯកជនទាំងឡាយមិនទាន់មានតម្លាភាពពេញលេញជាដើម។ ដូចដែលបានស្នើឡើងដោយភាគីពាក់ព័ន្ធដែលបានសម្ភាស វិធីសាស្ត្រប្រកបដោយតុល្យភាពដែលរួមបញ្ចូលការអភិរក្សដែលដឹកនាំដោយសហគមន៍ផ្ទាល់, បទប្បញ្ញត្តិតឹងរ៉ឹង, និងការវិនិយោគប្រកបដោយនិរន្តរភាព គឺមានសារៈសំខាន់ណាស់ក្នុងការការពារប្រព័ន្ធអេកូឡូស៊ីឆ្នេរសមុទ្រប្រទេសកម្ពុជា ខណៈពេលដែលជំរុញកំណើនប្រកបដោយសមធម៌។ ការពង្រឹងសហគមន៍គ្រប់គ្រងធនធានធម្មជាតិ, ការលើកកម្ពស់តម្លាភាពនៅក្នុងដំណើរការ វ.ហ.ប. និងការពង្រឹងការអនុវត្តច្បាប់ឱ្យមានប្រសិទ្ធភាពខ្ពស់ គឺជាអាទិភាពបន្ទាន់។

## ៤. ការពិភាក្សាសំខាន់ៗ

- ការអនុវត្តបទប្បញ្ញត្តិស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននៅប្រទេសកម្ពុជាមិនពេញលេញនិងគ្រប់គ្រាន់ ដែលបណ្តាលឱ្យមានគម្លាតនិងកង្វះខាតច្រើនក្នុងការចូលរួមពីសហគមន៍, និងការបង្ហាញជាសាធារណៈ និងការតាមដានត្រួតពិនិត្យលើការអនុវត្តតាមរបាយការណ៍ វ.ហ.ប. ជាដើម។ អាណត្តិនិងខ្លឹមសារដែលមានចែងក្នុងក្រមបរិស្ថាននិងធនធានធម្មជាតិ និងគតិយុត្តមួយចំនួនដែលទាមទារឱ្យមានការចូលរួមពីសហគមន៍ឱ្យបានសមស្របនៅក្នុងដំណើរការ វ.ហ.ប., ការបង្ហាញជាសាធារណៈនៃរបាយការណ៍ វ.ហ.ប., ការបិតផ្សាយលិខិតឯកភាពលើរបាយការណ៍ វ.ហ.ប. នៅលើទីតាំងគម្រោង, និងការត្រួតពិនិត្យជាប្រចាំលើការអនុវត្តតាមរបាយការណ៍ វ.ហ.ប. មិនត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាពខ្ពស់នៅឡើយទេ។
- តំបន់ឆ្នេរសមុទ្រ និងតាមព្រែកនានារបស់ប្រទេសកម្ពុជាបានប្រឈមមុខនឹងសម្ពាធពីខាងក្រៅយ៉ាងខ្លាំងអស់រយៈពេលជិតមួយទសវត្សរ៍ ដោយបង្កើតបរិយាកាសប្រកួតប្រជែងសម្រាប់សហគមន៍មូលដ្ឋាន ដែលពឹងផ្អែកលើធនធានទាំងនោះ។ ការភ័យខ្លាច និងការខកចិត្តពីជម្លោះដែលមិនទាន់ដោះស្រាយជាមួយនឹងតួអង្គខាងក្រៅដ៏មានឥទ្ធិពល ដូចជាឥស្សរជននយោបាយ និងបុគ្គលដែលមានទ្រព្យសម្បត្តិជាដើម បានក្លាយជាបន្ទុករបស់សហគមន៍ទាំងនេះ។ គម្រោងអាជីវកម្មដូចជាការបូមខ្សាច់ និងការចាក់ដីចូលតំបន់ឆ្នេរសមុទ្របានបណ្តាលឱ្យមានការរិចរិលបរិស្ថាន បំផ្លាញជម្រកសត្វសមុទ្រដ៏សំខាន់ និងគំរាមកំហែងដល់សន្តិសុខស្បៀង និងស្ថិរភាពសេដ្ឋកិច្ចរបស់ប្រជាពលរដ្ឋមូលដ្ឋាន។
- សហគមន៍តាមតំបន់ឆ្នេរសមុទ្រ ដែលពឹងផ្អែកខ្លាំងលើធនធានជលផលសមុទ្រសម្រាប់ចិញ្ចឹមជីវិតរបស់ពួកគេ ប្រឈមនឹងភាពងាយរងគ្រោះកាន់តែខ្លាំងឡើង ដោយសារការអនុវត្តដែលមិនស្ថិតស្ថេរដូចជាការនេសាទហួសប្រមាណ ការបំពុលសមុទ្រផ្សេងៗ និងការបំផ្លិចបំផ្លាញទីជម្រករបស់ប្រភេទនានា។ ការថយចុះនេះបានគំរាមកំហែងដល់ស្ថិរភាពសេដ្ឋកិច្ច ជាពិសេសសម្រាប់គ្រួសារនៅជនបទដែលពឹងផ្អែកលើធនធានទាំងនេះ។
- សហគមន៍មូលដ្ឋានមានកង្វះខាតច្រើនលើធនធានហិរញ្ញវត្ថុ និងសម្ភារៈដែលរារាំងសមត្ថភាពរបស់ពួកគេក្នុងការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយប្រសិទ្ធភាព។ ការថយចុះនៃការគាំទ្រពីអង្គការមិនមែនរដ្ឋាភិបាលក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ បានធ្វើឱ្យបញ្ហានេះកាន់តែធ្ងន់ធ្ងរឡើង ដោយទុកឱ្យសហគមន៍ងាយរងគ្រោះទៅនឹងសម្ពាធពីខាងក្រៅដ៏មានឥទ្ធិពលដែលសម្លឹងឃើញតែផលប្រយោជន៍ពីសហគមន៍ តាមរយៈការអនុវត្តគម្រោងវិនិយោគមួយចំនួនដែលអាចបំផ្លាញដល់បរិស្ថាន និងធនធានធម្មជាតិនៅមូលដ្ឋាន។
- ការអនុវត្តច្បាប់នៅក្នុងខេត្តជាប់មាត់សមុទ្រត្រូវបានគេយល់ថាគ្មានប្រសិទ្ធភាព និងមានភាពលំអៀងដែលនាំឱ្យខ្វះការជឿទុកចិត្តលើប្រព័ន្ធច្បាប់ និងធ្វើឱ្យប៉ះពាល់ដល់កិច្ចខិតខំប្រឹងប្រែងសម្រាប់ការគ្រប់គ្រងធនធានប្រកបដោយនិរន្តរភាព។ ការបាត់បង់ជំនឿទុកចិត្តនេះអាចបណ្តាលឱ្យមានការបែកបាក់សង្គម និងបង្កើនវិសមភាពកាន់តែខ្លាំង។
- ការប្រែប្រួលអាកាសធាតុជាផ្នែកមួយនៃការកើនឡើងនូវភាពរិចរិលនៃធនធានសមុទ្រ, រំខានដល់ការរស់នៅប្រចាំថ្ងៃ និងឱនភាពនៃឱកាសសេដ្ឋកិច្ចសម្រាប់សហគមន៍ទាំងឡាយ។ ព្រឹត្តិការណ៍អាកាស

ជាតុធ្ងន់ធ្ងរ កាន់តែមានស្ថានភាពរីករាលឡើងដោយការប្រែប្រួលអាកាសធាតុ ដែលបង្កជាបញ្ហាប្រឈមបន្ថែមទៀតដល់ការនេសាទបែបប្រពៃណីរបស់ប្រជានេសាទមូលដ្ឋាន។

- ជាចុងក្រោយ កង្វះតម្លាភាព និងគណនេយ្យភាពអំពីគម្រោងវិនិយោគឯកជន បង្កឱ្យមានការព្រួយបារម្ភអំពីផលប៉ះពាល់របស់គម្រោងទាំងនោះលើសហគមន៍មូលដ្ឋាន និងបរិស្ថាន។ អវត្តមាននៃព័ត៌មានជាសាធារណៈអំពីគម្រោងវិនិយោគ និងគោលនយោបាយអំពីបរិស្ថាន សង្គម និងអភិបាលកិច្ចបង្ហាញពីការប្តេជ្ញាចិត្តមិនគ្រប់គ្រាន់ចំពោះការអនុវត្តប្រកបដោយនិរន្តរភាព និងចោទជាសំណួរអំពីតួនាទីនិយតកម្ម និងការតាមដានការអនុវត្តនានារបស់ក្រសួង-ស្ថាប័ននៃរដ្ឋាភិបាលកម្ពុជា។

## ៥. សេចក្តីសន្និដ្ឋាន

ធនធានជលផលសមុទ្រមានសារៈសំខាន់ណាស់សម្រាប់សហគមន៍តំបន់ឆ្នេរក្នុងប្រទេសកម្ពុជា ប៉ុន្តែការនេសាទហួសប្រមាណ ការបំផ្លិចបំផ្លាញទីជម្រកប្រភេទសត្វនានា និងការគ្រប់គ្រងធនធានគ្មានប្រសិទ្ធភាពបានគំរាមកំហែងដល់អនាគតរបស់សហគមន៍មូលដ្ឋានទាំងនោះ។ លើសពីនេះ កង្វះការអនុវត្ត វ.ហ.ប. ប្រកបដោយប្រសិទ្ធភាព បង្កការគំរាមកំហែងកាន់តែទូលំទូលាយដល់សេចក្តីប្រាថ្នានៃការអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់ប្រទេសកម្ពុជា។ អវត្តមាននៃការវាយតម្លៃត្រឹមត្រូវអាចនាំឱ្យមានការរិចរិលបរិស្ថាន ការបាត់បង់ជីវៈចម្រុះ និងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ជីវភាពរស់នៅរបស់សហគមន៍មូលដ្ឋាន ជាពិសេសអ្នកដែលពឹងផ្អែកលើធនធានធម្មជាតិសម្រាប់ចិញ្ចឹមជីវិតរបស់ពួកគេ។ ផលវិបាកនៃការធ្វេសប្រហែសទាំងនេះមិនត្រឹមតែធ្វើឱ្យប៉ះពាល់ដល់ប្រព័ន្ធអេកូឡូស៊ីក្នុងស្រុកប៉ុណ្ណោះទេ ថែមទាំងបង្កើតវដ្តនៃភាពក្រីក្រ និងការផ្លាស់ប្តូរសិទ្ធិក្នុងសហគមន៍ដែលពឹងផ្អែកលើធនធានទាំងនេះផងដែរ។

ដើម្បីដោះស្រាយបញ្ហាប្រឈមទាំងនេះ ការពង្រឹងក្របខណ្ឌ វ.ហ.ប. ដោយបញ្ចូលវិធីសាស្ត្រវាយតម្លៃឱ្យបានម៉ត់ចត់ ដំណើរការត្រួតពិនិត្យជាប្រចាំ និងយន្តការពង្រឹងការអនុវត្តគឺជាតម្រូវការចាំបាច់បំផុត។ ការចូលរួមពីសហគមន៍មូលដ្ឋាននៅក្នុងដំណើរការ វ.ហ.ប. ក៏អាចលើកកម្ពស់តម្លាភាព និងគណនេយ្យភាពផងដែរ ដោយធានាថាសំឡេងរបស់អ្នកដែលរងផលប៉ះពាល់ខ្លាំងបំផុតដោយគម្រោងអភិវឌ្ឍន៍ត្រូវបានស្តាប់ និងពិចារណាក្នុងការសម្រេចចិត្ត។ លើសពីនេះ ការជំរុញកិច្ចសហប្រតិបត្តិការរវាងភ្នាក់ងាររដ្ឋាភិបាល អង្គការសង្គមស៊ីវិល និងដៃគូអន្តរជាតិ អាចជួយសម្រួលដល់ការចែករំលែកចំណេះដឹង និងការអនុវត្តល្អបំផុតក្នុងការគ្រប់គ្រងបរិស្ថាននៅតាមតំបន់មូលដ្ឋាន។ កម្មវិធីបណ្តុះបណ្តាលដែលមានគោលបំណងកសាងសមត្ថភាពសម្រាប់អ្នកពាក់ព័ន្ធក្នុងស្រុកអាចផ្តល់អំណាចឱ្យភាគីពាក់ព័ន្ធចូលរួមយ៉ាងសកម្មក្នុងដំណើរការ វ.ហ.ប. ដោយលើកកម្ពស់វប្បធម៌នៃនិរន្តរភាពដែលស្របតាមតម្រូវការក្នុងស្រុក និងស្តង់ដារពិភពលោក។

ទីបំផុត ក្របខណ្ឌនៃ វ.ហ.ប. ដែលសង្កត់ធ្ងន់លើការគ្រប់គ្រងបែបសកម្ម ជៀសជាងតាមបែបប្រតិកម្ម នឹងមានសារៈសំខាន់សម្រាប់ការលើកកម្ពស់ការអភិវឌ្ឍប្រកបដោយចីរភាពនៅប្រទេសកម្ពុជា។ តាមរយៈការផ្តល់អាទិភាពដល់ការការពារបរិស្ថាន និងការចូលរួមរបស់សហគមន៍ ប្រទេសនេះអាចស្វែងរកដំណោះស្រាយលើបញ្ហាប្រឈមក្នុងការអភិវឌ្ឍន៍របស់ខ្លួន ស្របពេលនឹងការអភិរក្សបេតិកភណ្ឌធម្មជាតិ និងការលើកកម្ពស់គុណភាពជីវិតសម្រាប់ប្រជាពលរដ្ឋទាំងអស់របស់ខ្លួន។ អភិបាលកិច្ចរឹងមាំ ការអនុវត្ត

ច្បាប់ និងយន្តការ (សម្រាប់ការគ្រប់គ្រងតំបន់ឆ្នេរ និងបទប្បញ្ញត្តិស្តីពី វ.ហ.ប.) ការគ្រប់គ្រងធនធានផ្អែកលើសហគមន៍ និងស្ថាប័នហិរញ្ញវត្ថុនានា គឺចាំបាច់ដើម្បីការពារការរិចរិលបរិស្ថាន និងអស្ថិរភាពសេដ្ឋកិច្ចសង្គម។ ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ និងកង្វះតម្លាភាពក្នុងគម្រោងវិនិយោគឯកជនតាមតំបន់ឆ្នេរសមុទ្រ បង្កការព្រួយបារម្ភអំពីគណនេយ្យភាពអាជីវកម្ម និងការអនុវត្តមិនទទួលខុសត្រូវ។

## ៦. អនុសាសន៍

- រដ្ឋាភិបាលគួរតែពង្រឹងកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ដើម្បីបង្កើនការអនុវត្តច្បាប់ តម្លាភាព និងគណនេយ្យភាពនៅក្នុងតំបន់ឆ្នេរ ដោយបង្កើត ឬពង្រឹងស្ថាប័នត្រួតពិនិត្យឯករាជ្យ ដែលមានភារកិច្ចត្រួតពិនិត្យនិងការអនុវត្តច្បាប់បរិស្ថានប្រកបដោយប្រសិទ្ធភាព។
- ក្រសួងបរិស្ថានគួរតែបន្តយ៉ាងសកម្មក្នុងការលើកកម្ពស់ប្រសិទ្ធភាពនៃច្បាប់ការពារបរិស្ថាន ជាពិសេសទាក់ទងនឹងការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រ។ ការណ៍នេះរួមបញ្ចូលទាំងការអនុវត្តបទប្បញ្ញត្តិតឹងរ៉ឹងដែលមានគោលបំណងរារាំងការកេងប្រវ័ញ្ចធនធានធម្មជាតិ។
- ដើម្បីលើកកម្ពស់តម្លាភាព និងគណនេយ្យភាពឱ្យកាន់តែច្រើននៅក្នុងដំណើរការ វ.ហ.ប. ក្រសួងបរិស្ថានគួរតែបន្តប្តេជ្ញាក្នុងការបង្ហាញព័ត៌មានដ៏ទូលំទូលាយទាក់ទងនឹងនីតិវិធីនិងដំណើរការ, វ.ហ.ប. របាយការណ៍ វ.ហ.ប., និងសកម្មភាពតាមដានត្រួតពិនិត្យដែលកំពុងបន្តអនុវត្ត។ ការប្តេជ្ញាចិត្តនេះអនុលោមតាមក្រមបរិស្ថាន និងធនធានធម្មជាតិ ដែលសង្កត់ធ្ងន់លើតម្រូវការសម្រាប់ការទទួលបានព័ត៌មានជាសាធារណៈ។
- ក្រសួងបរិស្ថានត្រូវបន្តប្តេជ្ញាយ៉ាងស្វាហាប់ក្នុងការចូលរួមជាមួយភាគីពាក់ព័ន្ធសំខាន់ៗ ជាពិសេសសហគមន៍មូលដ្ឋាន និងអាជ្ញាធរក្នុងការពិគ្រោះយោបល់ទាក់ទងនឹងការពិភាក្សាអំពី វ.ហ.ប.។ វិធីសាស្រ្តសហការនេះធានាថា សំឡេងរបស់អ្នកដែលរងផលប៉ះពាល់ខ្លាំងបំផុតដោយការអភិវឌ្ឍន៍នៅតាមតំបន់ឆ្នេរសមុទ្រត្រូវបានស្តាប់ និងពិចារណា។
- បន្ថែមពីលើការអនុវត្ត វ.ហ.ប. ឱ្យបានដ៏រឹងមាំ ការតាមដាន និងការវាយតម្លៃជាបន្តនៃផលប៉ះពាល់របស់គម្រោងទៅលើសហគមន៍ និងបរិស្ថាន ក៏មានសារៈសំខាន់ណាស់។ កិច្ចការនេះគួរតែពាក់ព័ន្ធនឹងការរាយការណ៍ជាទៀងទាត់ ដែលមានរចនាសម្ព័ន្ធច្បាស់លាស់ ដោយអ្នកអភិវឌ្ឍន៍គម្រោងទៅកាន់សហគមន៍នេសាទ សមាជិកសហគមន៍ និងអ្នកពាក់ព័ន្ធផ្សេងទៀត។
- ដើម្បីលើកកម្ពស់ការអនុវត្តការវិនិយោគប្រកបដោយបរិយាបន្ន និងតម្លាភាពបន្ថែមទៀត រដ្ឋាភិបាលត្រូវតែបង្កើត ឬដាក់ចេញបទប្បញ្ញត្តិទាក់ទងនឹងអាជីវកម្ម ការអភិវឌ្ឍ ឬការវិនិយោគ ដែលតម្រូវឱ្យគម្រោងទាំងអស់ (នៅតាមតំបន់ឆ្នេរ) បង្ហាញព័ត៌មានសំខាន់ៗអំពីហិរញ្ញវត្ថុ គំរូអាជីវកម្ម និងគោលនយោបាយស្តីពីបរិស្ថាន សង្គម និងអភិបាលកិច្ចរបស់ពួកគេជាដើម។ តម្លាភាពនេះគឺមានសារៈសំខាន់សម្រាប់ធានាថាសហគមន៍មូលដ្ឋាន និងភាគីពាក់ព័ន្ធទាំងអស់យល់ដឹងយ៉ាងច្បាស់អំពីគម្រោង និងចូលរួមយ៉ាងសកម្មក្នុងដំណើរការធ្វើការសម្រេចចិត្តដែលប៉ះពាល់ដល់បរិស្ថាន ធនធានធម្មជាតិនិងជីវភាពរស់នៅរបស់ពួកគេ។

- លើសពីនេះ ការចូលរួមពីសហគមន៍ដែលអនុវត្តដោយអ្នកវិនិយោគ ក្រសួងបរិស្ថាន និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គួរតែពង្រីកលើសពីដំណាក់កាលធ្វើផែនការ និងការអនុវត្តគម្រោងវិនិយោគដំបូង ឬក្នុងដំណើរការ វ.ហ.ប. ប៉ុណ្ណោះ។ ការសន្ទនា និងការជួបប្រជុំជាប្រចាំជាចាំបាច់រវាងអ្នកវិនិយោគ មន្ត្រីរដ្ឋាភិបាល និងសហគមន៍មូលដ្ឋាន មានសារៈសំខាន់ក្នុងការកសាងទំនុកចិត្ត និងធានាបានថាផលប្រយោជន៍របស់ភាគីទាំងអស់ត្រូវបានពិចារណាក្នុងអំឡុងពេលវដ្តនៃការវិនិយោគ។
- ការបង្កើតយន្តការសម្រាប់ដោះស្រាយបណ្តឹងសារទុក្ខដោយគម្រោងក៏មានសារៈសំខាន់ណាស់ដែរ។ សហគមន៍គួរមានសិទ្ធិចូលប្រើបណ្តាញផ្លូវការដើម្បីរាយការណ៍ពីកង្វល់ ឬសារទុក្ខទាក់ទងនឹងផលប៉ះពាល់របស់គម្រោងដោយអនុលោមតាមក្រមបរិស្ថាន និងធនធានធម្មជាតិឆ្នាំ២០២៣។
- រដ្ឋាភិបាលគួរតែធានានូវការអភិវឌ្ឍន៍សេដ្ឋកិច្ចប្រកបដោយចីរភាពនៅកម្ពុជា តាមរយៈការលើកកម្ពស់គម្រោងវិនិយោគដែលមានលក្ខណៈគិតគូច្រើនអំពីបរិស្ថាន, លើកទឹកចិត្តអ្នកវិនិយោគឯកជនឱ្យអនុវត្តគំរូអាជីវកម្មប្រកបដោយនិរន្តរភាព, និងបង្កើតក្របខណ្ឌគ្រប់គ្រងធនធានប្រកបដោយចីរភាព ដែលធ្វើឱ្យមានតុល្យភាពកំណើនសេដ្ឋកិច្ចជាមួយនឹងការការពារបរិស្ថាន និងជីវភាពរស់នៅក្នុងស្រុក ដោយផ្តោតលើវិស័យទេសចរណ៍ និងគំនិតផ្តួចផ្តើមអភិរក្សសហគមន៍ជាដើម។
- ការបណ្តុះបណ្តាលសមត្ថភាព និងការគាំទ្រផ្នែកហិរញ្ញវត្ថុនៅតែមានសារៈសំខាន់សម្រាប់សហគមន៍ការពារធនធានធម្មជាតិ ដែលអាចត្រូវបានប្រើដើម្បីបង្កើនអភិបាលកិច្ច និងលើកទឹកចិត្តដល់ការចូលរួមរបស់សហគមន៍ក្នុងសកម្មភាពអភិរក្សនៅមូលដ្ឋានឱ្យកាន់តែមានប្រសិទ្ធភាព។
- គំនិតផ្តួចផ្តើមការកសាងសមត្ថភាពគួរតែត្រូវបានរៀបចំឡើងដើម្បីបំពាក់បំប៉នសហគមន៍ ជាមួយនឹងជំនាញ និងចំណេះដឹងចាំបាច់ ដើម្បីស្វែងយល់អំពីភាពស្មុគស្មាញ និងការស្វែងរកព័ត៌មាននៃដំណើរការវិនិយោគ។
- ការផ្តល់សិទ្ធិអំណាចដល់សហគមន៍ការពារធនធានធម្មជាតិក្នុងការត្រួតពិនិត្យ និងរាយការណ៍អំពីផលប៉ះពាល់បរិស្ថាន និងសង្គមរបស់គម្រោងវិនិយោគ គឺមានសារៈសំខាន់សម្រាប់ការលើកកម្ពស់គណនេយ្យភាព និងតម្លាភាព តាមរយៈការកសាងសមត្ថភាពពាក់ព័ន្ធ ការតាមដានជាប្រចាំពីសំណាក់ដៃគូ និងកិច្ចប្រជុំសហគមន៍ជាមួយអាជ្ញាធរ ដើម្បីចែករំលែកកង្វល់ និងសំណើសម្រាប់ការឆ្លើយតបនានា។
- លើសពីនេះ វិនិយោគិនគួរតែពិចារណាបង្កើតយន្តការគាំទ្រ ឬអភិវឌ្ឍន៍រួមគ្នាក្នុងស្រុកជាមួយអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ឬគំនិតផ្តួចផ្តើមនានាដែលស្របតាមផលប្រយោជន៍របស់សហគមន៍។ ការរួមចំណែកទាំងនេះអាចគាំទ្រដល់ការអប់រំ ការថែទាំសុខភាព ឬសេវាសង្គមផ្សេងទៀតដែលលើកកម្ពស់គុណភាពជីវិតសម្រាប់ប្រជាពលរដ្ឋនៅមូលដ្ឋាន។
- ជាពិសេស រដ្ឋាភិបាលត្រូវរៀបចំយុទ្ធសាស្ត្រឡើងវិញនូវគោលនយោបាយ និងអាទិភាពនៃការអភិវឌ្ឍដើម្បីទាក់ទាញអ្នកផ្តល់ហិរញ្ញប្បទានដែលប្តេជ្ញាចិត្តខ្ពស់ចំពោះស្តង់ដារនៃការអនុវត្តលើបរិស្ថាន សង្គម និងអភិបាលកិច្ច។ ការណ៍នេះអាចសម្រេចបានដោយការផ្តល់ការលើកទឹកចិត្តសម្រាប់ការវិនិយោគដែលមានទំនួលខុសត្រូវ ដូចជាការបន្ធូរបន្ថយពន្ធ ឬជំនួយសម្រាប់គម្រោងដែលផ្តល់អាទិភាពដល់និរន្តរភាព និងទំនួលខុសត្រូវសង្គម។

- ការពង្រឹងការពិគ្រោះយោបល់ប្រកបដោយអត្ថន័យជាមួយសហគមន៍ដែលរងផលប៉ះពាល់ និងអង្គការសង្គមស៊ីវិល (CSOs) គឺចាំបាច់ដើម្បីធានាថាកង្វល់ និងការចូលរួមរបស់មូលដ្ឋានត្រូវបានទទួលស្គាល់យ៉ាងពេញលេញ។ វិធីសាស្ត្រនេះតំណាងឱ្យយុទ្ធសាស្ត្រឈ្នះ-ឈ្នះ និងជំរុញឱ្យមានការចូលរួមរបស់ប្រជាពលរដ្ឋ និងការចូលរួមរបស់អង្គការសង្គមស៊ីវិលក្នុងការសម្រេចចិត្តលើការអភិវឌ្ឍ និងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន។
- ការលើកទឹកចិត្តដល់ស្ថាប័នហិរញ្ញវត្ថុឱ្យអនុម័ត និងអនុវត្តក្របខណ្ឌបរិស្ថាន សង្គម និងអភិបាលកិច្ចដ៏រឹងមាំ ដោយធ្វើការបង្កើនការបញ្ជាក់អត្តសញ្ញាណល្អ និងគណនេយ្យភាពប្រកបដោយនិរន្តរភាពរបស់ពួកគេ តាមរយៈការផ្តល់អាទិភាពដល់គម្រោងជាមួយនឹងការប្តេជ្ញាចិត្តលើបរិស្ថាន សង្គម និងអភិបាលកិច្ចដ៏មុតមាំ និងការជំរុញការអនុវត្តការវិនិយោគប្រកបដោយការទទួលខុសត្រូវខ្ពស់។
- ការលើកកម្ពស់ការយល់ដឹងជាសាធារណៈអំពីគោលនយោបាយបរិស្ថាន សង្គម និងអភិបាលកិច្ច និងការវិនិយោគប្រកបដោយការទទួលខុសត្រូវ គឺជាកត្តាសំខាន់សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាពនៅប្រទេសកម្ពុជា។ រដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល និងវិស័យឯកជនអាចលើកទឹកចិត្តឱ្យមានការផ្លាស់ប្តូរឆ្ពោះទៅរកឥរិយាបថវិនិយោគប្រកបដោយការទទួលខុសត្រូវខ្ពស់ ដោយបង្កើនការយល់ដឹងអំពីគោលគំនិតទាំងនេះ។

* * * * *


ឯកសារនេះត្រូវបានរៀបរៀងឡើងក្រោមកិច្ចសហការគាំទ្រមូលនិធិដោយសហភាពអឺរ៉ុប។ រាល់ខ្លឹមសារ និងអត្ថន័យនៅក្នុងឯកសារនេះ គឺជាការទទួលខុសត្រូវរបស់អ្នកនិពន្ធ ហើយមិនឆ្លុះបញ្ចាំងអំពីទស្សនៈរបស់អង្គការវេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា និងអង្គការអាក់សិនអេតកម្ពុជា ដែលជាសមាជិក នៃគម្រោងសម្ព័ន្ធយុត្តិធម៌ហិរញ្ញវត្ថុកម្ពុជា និងសហភាពអឺរ៉ុបនោះទេ។



*សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង÷*

វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា

ទូរស័ព្ទលេខ ០២៣ ២១៤ ៤២៩

គេហទំព័រ: www.ngoforum.org.kh

អង្គការអាក់សិនអេតកម្ពុជា

ទូរស័ព្ទលេខ ០២៣ ២១១ ៤៦១

គេហទំព័រ: cambodia.actionaid.org



Supported By

Diakonia

Sweden Sverige

Co-funded by the European Union